គម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូង
SOUTHERN CARDAMOM REDD+ PROJECT

WILDLIFE ALLIANCE

WILDLIFE WORKS

# គម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូង

## សេចក្តីសង្ខេបនៃរបាយការណ៍ត្រួតពិនិត្យលើកទី៤

គម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូង ត្រូវបានផ្តួចផ្តើមរៀបចំឡើងដើម្បីជួយជំរុញឲ្យមានការកាត់បន្ថយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ការរក្សាអភិរក្សជីវចម្រុះ និងបង្កើតឲ្យមានជម្រើសជីវភាពរស់នៅ ស្របតាមផែនការរបស់អង្គការសហប្រជាជាតិ ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ និងរេចរិលព្រៃឈើ (រេដបូក) ។ ផ្ទៃដីទីតាំងគម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូងមានទំហំ ៤៩៣,៥៨២.៦ ហត ក្នុងនោះមួយផ្នែកស្ថិតនៅក្នុងអតីតៈឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង និងមួយផ្នែកទៀតស្ថិតក្នុងដែនជម្រកសត្វព្រៃតាតៃ ហើយនឹងផ្តល់នូវការការពារចំណែកដ៏សំខាន់នៃតំបន់អេកូព្រៃទឹកភ្លៀងតំបន់ជួរភ្នំក្រវាញ ជាទីកន្លែងអភិរក្សជីវចម្រុះដ៏សំខាន់ជាងគេមួយក្នុងចំណោមទីកន្លែងអភិរក្សជីវចម្រុះដ៏សំខាន់ៗជាងគេទាំង ២០០ ទីតាំង នៅលើភពផែនដី ។ តំបន់គណនេយ្យគម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូងត្រូវបានកំណត់ដោយវិធីសាស្រ្តស្តង់ដារផ្ទៀងផ្ទាត់កាបូនមានទំហំ ៤៤២,៨៧១ ហត ។ គម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូង ស្ថិតនៅចំចំណុចសំខាន់បំផុត នៃឧបទ្វីបឥណ្ឌូ-ភូមា ជាទីតាំងសំបូរទៅដោយជីវចម្រុះដ៏សំខាន់មួយ ក្នុងចំណោមទីតាំងជីវចម្រុះសំខាន់ៗទាំង ៣៤ កន្លែង នៅលើពិភពលោក និងជាទីជម្រាលដ៏ចាំបាច់នៅឈូងសមុទ្រថៃគ្របដណ្តប់ដោយគម្របព្រៃឈើប្រភេទផ្សេងៗគ្នា រួមមានទាំងព្រៃស្រោងពណ៌បៃតងជានិច្ច និងព្រៃស្រល់ខ្ពង់រាប រហូតដល់គម្របព្រៃតំបន់ទំនាប មានព្រៃស្នាច់តំបន់ដីសើម វាលស្មៅលិចទឹក បឹង និងព្រៃកោងកាងមាត់សមុទ្រ ។ គម្របព្រៃចម្រុះប្រភេទនេះគឺជាជម្រកសត្វដែលមានចំនួនយ៉ាងហោចណាស់ ៥២ ប្រភេទ យោងតាមបញ្ជីថនិកសត្វ បក្សី និងសត្វល្មូនដែលកំពុងរងគ្រោះជាសកល របស់អង្គការអាយ-យូ-ស៊ី-អិន ដែលក្នុងនោះ រួមមាន ក្រពើភ្នំ និងក្រុមសត្វដំរីអាស៊ីមួយហ្វូងអាចរស់នៅបាន ក្នុងចំណោមក្រុមហ្វូងសត្វដំរីកម្ពុជាទាំងពីរហ្វូង ។ តំបន់ទេសភាពនេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជាឱកាសនៃការដោះលែងសត្វខ្លាឲ្យទៅរស់នៅក្នុងព្រៃធម្មជាតិវិញផងដែរ ។

ទីជម្រាលប្រភពទឹកតំបន់ជួរភ្នំក្រវាញខាងត្បូង មានសារៈសំខាន់សម្រាប់មច្ឆាជាតិ នៅឈូងសមុទ្រថៃ ដោយសារទីជម្រាលនេះបានផ្តល់ទឹកសាប ដល់ប្រភេទព្រៃកោងកាងជាប់ៗគ្នាមានទំហំធំជាងគេដែលនៅសេសសល់ នៅឈូងសមុទ្រនេះ នោះគឺដែនជម្រកសត្វព្រៃពាមក្រសោប ដែលជាជម្រកសម្រាប់មច្ឆាជាតិបង្កកំណើតដ៏សំខាន់នៅក្នុងតំបន់ ។ តំបន់នេះផ្តល់ចំណីអាហារដល់ប្រទេសថៃ កម្ពុជា និងវៀតណាម និងបំពេញតួនាទីនិយ័តកម្មអាកាសធាតុនៅឧបទ្វីបអាស៊ីអគ្នេយ៍ ។ កាន់តែពិសេសជាងនេះទៅទៀត គម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូងមានផ្លូវទឹកធំៗចំនួន ២២ ដែលអាចផ្គត់ផ្គង់ទឹកសម្រាប់ភូមិចំនួន ៣,៨០០ នៅក្នុងខេត្តចំនួន ៦ ។ មកទល់ពេលនេះ គម្រោងនេះបានផ្តល់ការគាំទ្រដោយផ្ទាល់ដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋចំនួន ២៩ ភូមិ ស្ថិតក្នុង ១៣ ឃុំ នៅតាមបរិវេណនិងជុំវិញទីតាំងគម្រោង ។ សហគមន៍ទាំងនេះមានចំនួនគ្រួសារប្រជាពលរដ្ឋសរុបរួម ៤,៧១៩ គ្រួសារ ស្មើនឹង ១៦,៤៩៥ នាក់ ។

អង្គការសម្ព័ន្ធមិត្តសត្វព្រៃបាននិងកំពុងជួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងជួរភ្នំក្រវាញខាងត្បូង តាំងពីឆ្នាំ ២០០២ មក ។ សកម្មភាពស្នូលរបស់អង្គការសម្ព័ន្ធមិត្តសត្វព្រៃរួមមានការល្បាតការពារព្រៃឈើ និងផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាលដើម្បីអនុវត្តការការពារព្រៃឈើ ។ អង្គការសម្ព័ន្ធមិត្តសត្វព្រៃក៏បានអនុវត្តសកម្មភាពអភិវឌ្ឍសហគមន៍ និងកម្មវិធីអប់រំផ្សព្វផ្សាយ ដើម្បីជួយសហគមន៍មូលដ្ឋាន ឲ្យធ្វើការផ្លាស់ប្តូរជីវភាពរស់នៅរបស់ខ្លួន ឲ្យមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការប្រើប្រាស់ធនធានធម្មជាតិដ៏សម្បូរបែប នៅក្នុងតំបន់ ប្រកបដោយនិរន្តភាព ។

ទោះបីជាព្រៃឈើតំបន់នេះមានសារៈសំខាន់ដ៏ធំធេងបែបនេះក្តី ការប្រែក្លាយដីព្រៃឈើជាទ្រង់ទ្រាយតូចៗឲ្យទៅជាដីកសិកម្មដែលគ្មានការត្រួតពិនិត្យគ្រប់គ្រង ធ្វើឡើងដោយជនចំណូលថ្មី និងការប្រែក្លាយដីព្រៃឈើឲ្យទៅជាចម្ការកសិ-

ឧស្សាហកម្មដោយវិស័យឯកជន បានធ្វើឲ្យតំបន់ជួរភ្នំក្រវាញខាងត្បូង ស្ថិតក្នុងចំណោមតំបន់ទេសភាពព្រៃឈើដែលកំពុងទទួលរងនូវការគំរាមកំហែងខ្លាំងជាងគេ នៅកម្ពុជា ។ សហគមន៍ប្រជាពលរដ្ឋនៅតាមទីជនបទរស់នៅអាស្រ័យទៅលើការផលិតនូវផលកសិកម្មខ្នាតតូច ដើម្បីគាំទ្រជីវភាពរស់នៅរបស់ខ្លួន ។ កង្វះឱកាសការងារសម្រាប់ប្រជាពលរដ្ឋ ដែលកំពុងតែមានចំនួនកើនឡើង រួមផ្សំនឹងកង្វះចំណេះដឹងក្នុងការកែលំអបច្ចេកទេសធ្វើកសិកម្ម បានធ្វើឲ្យប្រជាពលរដ្ឋមូលដ្ឋានកាប់ឆ្ការព្រៃ ដើម្បីដាំដំណាំពាណិជ្ជកម្ម ។

ដើមហេតុចំបងដែលនាំឲ្យមានការកាប់បំផ្លាញព្រៃឈើ គឺដោយសារតែមានតម្រូវការដីច្រើនសម្រាប់ធ្វើកសិកម្ម និងដាំដំណាំពាណិជ្ជកម្ម នៅក្នុងទីតាំងគម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូង និងក្នុងខេត្តកោះកុងទាំងមូល ។ ចំនួនមនុស្សនៅក្នុងខេត្ត និងនៅក្នុងតំបន់បានកើនឡើងយ៉ាងច្រើនគួរឲ្យកត់សម្គាល់ ក្នុងរយៈមួយទសវត្សចុងក្រោយនេះ ។ កំណើនចំនួនមនុស្សគឺបណ្តាលមកពីជនចំណូលថ្មី និងអត្រាកំណើតរបស់កុមារនៅក្នុងភូមិដែលនៅជុំវិញ ។ បច្ចុប្បន្ននេះ ចំណេះដឹងមូលដ្ឋាននៅមានកម្រិតទាប ដោយសារតែតម្រូវការពលកម្មកុមារ ដើម្បីជួយការងារដាំដុះក្នុងគ្រួសារ នៅពេលថ្ងៃ ដែលបង្កើតឲ្យមានវដ្តនៃភាពក្រីក្រ ព្រមទាំងបង្កឲ្យមានការកាប់បំផ្លាញព្រៃឈើផងដែរ ។ ដើមហេតុផ្សេងទៀតដែលនាំឲ្យមានការកាប់បំផ្លាញព្រៃឈើផងដែរនោះ រួមមាន ការកាប់ឈើខុសច្បាប់ ការប្រមូលអុស និងការផលិតធ្យូងជាដើម ។ សកម្មភាពទាំងនេះត្រូវបានប្រព្រឹត្តឡើងជាពិសេសដោយសហគមន៍មូលដ្ឋាន ដើម្បីបានប្រភពចំណូលបន្ថែម ។

វិធីសាស្ត្រសំខាន់ដើម្បីកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធនៅក្នុងតំបន់គម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូងត្រូវបានធ្វើឡើងតាមរយៈសិក្ខាសាលាស្តីពីផលប៉ះពាល់ជីវចម្រុះ និងសង្គម ដែលត្រូវបានរៀបចំឡើងនៅខេត្តកោះកុងកាលពីថ្ងៃទី ១៥-១៧ និងថ្ងៃទី ២៣-២៥ ខែសីហា ឆ្នាំ២០១៧ ។ សិក្ខាសាលានេះមានអ្នកចូលរួមសរុបចំនួន ៧៣ រូប ដែលត្រូវបានមន្ត្រីជំនាញក្នុងស្រុកបានកំណត់ថា ជាអ្នកដឹកនាំ ឬជាតំណាងរបស់ក្រុមអ្នកដែលពាក់ព័ន្ធគម្រោង ។ លើសពីនេះទៅទៀតចំណេះដឹងរបស់មន្ត្រីជំនាញនៃក្រុមអ្នកអនុវត្តគម្រោងក៏ត្រូវបានប្រើប្រាស់ផងដែរ ដើម្បីកំណត់អត្តសញ្ញាណអ្នកផ្សេងទៀតដែលពាក់ព័ន្ធនឹងគម្រោងដែរ តែមិនទាន់បានរកអត្តសញ្ញាណឃើញនៅក្នុងសិក្ខាសាលាស្តីពីផលប៉ះពាល់ជីវចម្រុះនិងសង្គមនាពេលកន្លងមក ។ មានការផ្លាស់ប្តូរការបរិយាយគម្រោងជុំវិញភាពញឹកញាប់នៃការត្រួតពិនិត្យសូចនាករសង្គម និងជីវចម្រុះភាគច្រើន ក្នុងអំឡុងពេលនៃការត្រួតពិនិត្យលើកទីពីរ ដោយធ្វើការផ្លាស់ប្តូរពីការត្រួតពិនិត្យ "ប្រចាំឆ្នាំ" ទៅជាការត្រួតពិនិត្យតាម "រយៈពេលត្រួតពិនិត្យ" វិញ ។ ការផ្លាស់ប្តូរនេះ គឺស្របទៅតាមភាពញឹកញាប់នៃការត្រួតពិនិត្យដែលបានកំណត់ក្នុងរបាយការណ៍ត្រួតពិនិត្យលើកទីមួយ។ ទោះបីជាបែបនេះក្តី ការផ្លាស់ប្តូរនេះមិនមានឥទ្ធិពលលើ ការអនុវត្តវិធីសាស្ត្រ ការបញ្ចូលបន្ថែម ឬភាពសមស្របនៃសេណារីយ៉ូជាមូលដ្ឋាននោះទេ ហើយចំនួនសូចនាករដែលត្រូវត្រួតពិនិត្យ ឬភាសានៃសូចនាករក៏មិនមានការផ្លាស់ប្តូរនោះដែរ ។

ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងទៅលើតំបន់ទេសភាពជួរភ្នំក្រវាញខាងត្បូង អង្គការសម្ព័ន្ធមិត្តសត្វព្រៃ រួមជាមួយក្រសួងបរិស្ថានបានសម្រេចបង្កើតជាគម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូងនេះឡើង ។ ការការពារគម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូង នឹងអាចសម្រេចទៅបានដរាបណានៅមានការបន្តការល្បាតពេញលេញនៅក្នុងតំបន់គម្រោង ក៏ដូចជាការផ្តល់នូវសកម្មភាពគម្រោងបន្ថែមដល់សហគមន៍ ដែលត្រូវបានត្រៀមរៀបចំឡើងក្នុងបំណងកាត់បន្ថយដើមហេតុនៃការបាត់បង់ព្រៃឈើ ។ ក្នុងនេះមានសកម្មភាពគម្រោងចំបងចំនួនពីរគឺ ការធ្វើកសិកម្មពេញលេញ និងអេកូទេសចរណ៍សហគមន៍ ។ សកម្មភាពគម្រោងទាំងពីរនេះនឹងជួយឲ្យមានភាពប្រសើរឡើងនូវសុវត្ថិភាពផ្នែកហិរញ្ញវត្ថុរបស់ សហគមន៍ព្រមទាំងធ្វើឲ្យថយចុះនូវការដកហូតធនធានមកប្រើប្រាស់ដោយគ្មាននិរន្តភាពក្នុងតំបន់គម្រោង ។ មូលនិធិ ក៏នឹងត្រូវបានផ្តល់ជូនផងដែរ ដើម្បីគាំទ្រអាហារូបករណ៍សម្រាប់កុមារពីគម្រោងសហគមន៍ ដើម្បីដោះស្រាយបញ្ហានៃដើមហេតុដ៏សំខាន់មួយនៃការកាប់បំផ្លាញព្រៃឈើដែលត្រូវបានកំណត់ក្នុងសិក្ខាសាលារបស់អ្នកពាក់ព័ន្ធ (ឧទាហរណ៍ អត្រានៃការទទួលបានការអប់រំទាប និងកង្វះឱកាសទទួលបានការអប់រំក្រោយបឋមសិក្សា) ។ មូលនិធិនេះនឹងផ្តល់ជូនសម្រាប់ប្រជាពលរដ្ឋសហគមន៍ បន្ថែមពីលើអត្ថប្រយោជន៍ដែលប្រជាពលរដ្ឋទទួលបានផ្ទាល់ពីគម្រោង ។ នៅក្នុងតំណាក់កាលត្រួតពិនិត្យ

លើកទី៤នេះ គម្រោងបានផ្តល់អាហារូបករណ៍ដល់និស្សិតថ្មីចំនួន ៧ នាក់ ក្នុងចំណោមនិស្សិតអាហារូបករណ៍សរុបចំនួន ១៧ នាក់ ចាប់តាំងពីកម្មវិធីអាហារូបករណ៍នេះបានចាប់ផ្តើមនៅឆ្នាំ ២០២១ ។ ក្នុងតំណាក់កាលត្រួតពិនិត្យលើកទី៤ នេះ គម្រោងបានធ្វើការធ្វើការបណ្តុះបណ្តាលដល់ ៣០៤ គ្រួសារ អំពីវិធីសាស្រ្តក្នុងការធ្វើកសិកម្ម និងកសិកម្មពេញលេញ ក៏ដូចជាការបណ្តុះបណ្តាលចំនួន ៨ ផ្សេងទៀតដល់អ្នកផ្តល់សេវាទេសចរណ៍ សរុបចំនួន ៥០១ គ្រួសារនៅក្នុងសហាគមន៍ជីផាត(៣៣២ គ្រួសារ) និងតំបន់អេកូទេសចរណ៍ឆាយអារ៉ែង (១៦៩ គ្រួសារ)។ ក្នុងដំណាក់កាលត្រួតពិនិត្យឆ្នាំ២០២២ ដល់ឆ្នាំ ២០២៣ គម្រោងបានផ្តល់ការងារដោយផ្ទាល់ដល់ ប្រជាពលរដ្ឋចំនួន ២៨ នាក់ និងកំពុងធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈការងារ។ ការលើកកម្ពស់ការយល់ដឹងអំពីសកម្មភាពរេដបូកជួរភ្នំក្រវាញខាងត្បូងក៏ត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំចំនួន ៣១៦ នៅក្នុងភូមិចំនួន ២៩ (១១ កិច្ចប្រជុំ/ភូមិ) និងមានអ្នកចូលរួម សរុប ៣,២៤១ នាក់ ដែលក្នុងនោះក៏មាននិស្សិតបានចូលរួមផងដែរ។ គម្រោងនេះក៏បានដាក់អោយដំណើរការនូវស្នាក់ការអនុវត្តច្បាប់ក្រសួងបរិស្ថានពេញលេញចំនួន ១០ ស្នាក់ការ និងអនុស្នាក់ការចំនួន ៣ នៅក្នុងតំបន់គម្រោងដែលមានបន្ទុកស្របច្បាប់ ក្នុងការការពារព្រៃឈើ និងសត្វព្រៃ។ មន្រ្តីឧទ្យានុរក្សបានបំពេញការងារប្រចាំការពេញម៉ោងនៅស្នាក់ការ ហើយធ្វើការល្បាតយ៉ាងតឹងរឹងជារៀងរាល់ថ្ងៃក្នុងតំបន់គម្រោង និងតំបន់លេចធ្លាយ ។ គិតត្រឹមឆ្នាំ ២០២៣ មានមន្រ្តីឧទ្យានុរក្សចំនួន ២៥៨ នាក់ទទួលបានការគាំទ្រពីគម្រោងបានបំពេញភារៈកិច្ចក្នុងតំបន់គម្រោង។ លើសពីនេះទៅទៀត កិច្ចប្រជុំរៀបចំផែនការប្រើប្រាស់ដីធ្លីចំនួន ៦ បានធ្វើឡើងដោយមានការចូលរួម និងការគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងបន្ទាប់មកទៀតមានការបោះបង្គោលកំណត់ព្រំដី ចំនួន ១៤៦ ដើមនៅតាមបណ្តោយព្រំប្រទល់ ដីសហាគមន៍ប្រវែង ២៦ គីឡូម៉ែត្រ ក្នុងឃុំឫស្សីជ្រុំ។

ផលប្រយោជន៍ផ្នែកអាកាសធាតុនៃគម្រោង រួមមានការកាត់បន្ថយការបញ្ចេញកាបូនក្នុងបរិមាណប្រមាណជា ៦,៨៩៤,២៣៩ តោន នៃសមមូលកាបូនឌីអុកស៊ីត ក្នុងដំណាក់កាលត្រួតពិនិត្យលើកទី៤នេះ និងបរិមាណប្រមាណជា ៣,៤៥២១,៤៧៥ តោន នៃសមមូលកាបូនឌីអុកស៊ីតនៅក្នុងរយៈកាលទាំងមូលរបស់គម្រោង ។ គម្រោងនឹងបង្កើតឲ្យមានសហអត្ថប្រយោជន៍ប្រកបដោយនិរន្តភាពទាំងសម្រាប់សហគមន៍ រួមទាំងជីវចម្រុះ ។ ឱកាសជីវភាពថ្មី និងប្រកបដោយនិរន្តភាព ដូចជាការផ្តល់ការងារដោយផ្ទាល់ ជម្រើសសកម្មភាពបង្កើតចំណូល និងការផ្តួចផ្តើមគំនិតវិនិយោគផ្នែកធុរកិច្ច នឹងចាត់ចែងរៀបចំឡើង ដើម្បីកាត់បន្ថយសំពាធទៅលើបរិស្ថាន ស្របពេលដែលសុខុមាលភាពរបស់សហគមន៍ត្រូវបានលើកកម្ពស់ក្នុងពេលតែមួយ ។ កម្មវិធីបន្ថែមនឹងត្រូវបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងសុវត្ថិភាពស្បៀង កែលំអអាគារសម្ភារៈបម្រើវិស័យសុខាភិបាល និងអប់រំ ក៏ដូចជាការលើកកម្ពស់ការយល់ដឹងពីបរិស្ថាន ។ សហប្រយោជន៍ផ្នែកជីវចម្រុះនឹងត្រូវសម្រេចបានតាមរយៈការការពារកាន់តែគត់ហ្មត់នូវមជ្ឈដ្ឋានបរិស្ថាន ជាពិសេសការបង្កើនសុវត្ថិភាព និងកែលំអការត្រួតពិនិត្យតាមដាន ។ គម្រោងក៏នឹងផ្តល់ការការពារជម្រកដើម និងសត្វជាច្រើនប្រភេទដែលត្រូវបានចុះនៅក្នុងបញ្ជីនៃអង្គការអាយ-យូ-ស៊ី-អិន មានដូចជា ដំរីអាស៊ី ខ្លាឃ្មុំធំ ខ្លាឃ្មុំតូច សំពោចធំ ខ្លាពពក និងឆ្កែព្រៃ ក៏ដូចជា សត្វល្មូនប្រភេទកំពុងរងគ្រោះ មានដូចជា ក្រពើភ្នំ និងអណ្តើកហ្លួង ។

សូមចូលទៅកាន់គេហទំព័ររបស់គម្រោង – https://southerncardamomredd.com/ និងទំព័រហ្វេសប៊ុក https://www.facebook.com/SouthernCardamomREDD ឬក៏ការិយាល័យគម្រោងដើម្បីមើលឯកសារគម្រោងពេញលេញ ។

| | |
|---|---|
| **ឈ្មោះគម្រោង** | គម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូង |
| **ទីតាំងគម្រោង** | ប្រទេសកម្ពុជា ខេត្តកោះកុង |

| | |
|---|---|
| អ្នកអនុវត្តគម្រោង | រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបរិស្ថាន<br>មន្ត្រីទំនាក់ទំនង: ជួប ប៉ារីស៍<br>អ៊ីម៉ែល: paris.ncg@gmail.com<br>ទូរស័ព្ទលេខ: ០១៧ ៣១៣ ៣៦៦ |
| សវនករ | EPIC Sustainability Services Pvt. Ltd.<br>R. B. Venkataramanaiah<br>អ៊ីម៉ែល: info@epicsustainability.com<br>ទូរស័ព្ទ: +91 95909 29936 |
| កាលបរិច្ឆេទគម្រោងចាប់ផ្តើម, ដំណាក់កាលគណនេយ្យឧស្ម័នផ្ទះកញ្ចក់ និងអាយុគម្រោង | កាលបរិច្ឆេទគម្រោងចាប់ផ្តើម: ០១ មិថុនា ២០១៥<br>ដំណាក់កាលគណនេយ្យឧស្ម័នផ្ទះកញ្ចក់: ០១ មិថុនា ២០១៥ - ៣១ ធ្នូ ២០៤៤<br>អាយុគម្រោង: ០១ មិថុនា ២០១៥ - ៣១ ធ្នូ ២០៤៤ |
| ដំណាក់កាលអនុវត្ត និងផ្ទៀងផ្ទាត់គម្រោង | ០១ មករា ២០២២ - ៣១ ធ្នូ ២០២៣ |
| ប្រវត្តិនៃស្តង់ដារកាបោន សហគមន៍ជីវចម្រុះ (CCB) | គម្រោងទទួលបានការឯកភាពទទួលស្គាល់នៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ ។<br>គម្រោងបានបញ្ចប់ការផ្ទៀងផ្ទាត់លើកដំបូង (M1) នៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ ។<br>គម្រោងបានបញ្ចប់ការផ្ទៀងផ្ទាត់លើកទីពីរ (M2) នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០២១ ។<br>គម្រោងបានបញ្ចប់ការផ្ទៀងផ្ទាត់លើកទីពីរ (M3) នៅថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០២២ ។ |
| ការបោះពុម្ពផ្សាយនៃស្តង់ដារកាបោន សហគមន៍ជីវចម្រុះ ដែលកំពុងត្រូវបានយកមកប្រើប្រាស់សម្រាប់ការវាយតម្លៃនេះ | គម្រោងនេះកំពុងត្រូវបានវាយតម្លៃ ក្រោមការបោះពុម្ពផ្សាយលើកទីបី នៃស្តង់ដារកាបោនសហគមន៍ជីវចម្រុះ |
| កម្រិតមាសនៃលក្ខណៈវិនិច្ឆ័យ | លក្ខណៈវិនិច្ឆ័យកម្រិតមាសពីរជាន់, អាកាសធាតុ និងជីវចម្រុះ |
| កាលបរិច្ឆេទបញ្ចប់ និងលេខទម្រង់របស់របាយការណ៍ត្រួតពិនិត្យតាមដាន | កាលបរិច្ឆេទ: ២៤ ខែតុលា ២០២៤<br>ទម្រង់: ២.១ |

| | |
|---|---|
| **សហគមន៍ ក្រុមសហគមន៍ និងអ្នកពាក់ព័ន្ធគម្រោងដែលបានកំណត់អត្តសញ្ញាណ** | **ឃុំ (ភូមិ) ដែលគម្រោងបានកំណត់អត្តសញ្ញាណ៖** កណ្តោល(សុវណ្ណាបៃតង) ដងពែង (ពោធិ៍បឹង-កំលត ពោធិ៍បឹង-ឆាយរាប បាក់អង្រុត) ជីផាត (ជីផាត ទឹកល្អក់ ជាំស្លា កំលត) អូរសោម (អូរសោម ឆាយលូក គៀនជង្រុក) តាសាល (រមាំងស) ចំបក់ (ក្រាំងចេក) ប្រឡាយ (ចំណារ ប្រឡាយ សំពេង ទ័ពឃ្លៃ) ជំនាប់ (ជំនាប់ ប្រកប្ញស្សី) ថ្មដូនពៅ (កោះ ព្រែកស្វាយ) អណ្តូងទឹក (ជីមាល) តាតៃក្រោម (អន្លង់វាក់ កោះអណ្តែត) ត្រពាំងរូង (ជីទំនាប ត្រពាំងរូង វាលតាភូ) ឫស្សីជ្រុំ (គគីរជ្រុំ ត្រពាំងឈើត្រាវ)<br><br>**ក្រុម/អ្នកពាក់ព័ន្ធសហគមន៍៖** អ្នកធ្វើកសិកម្ម អ្នកជុតធ្យូង អ្នករកខ្យុស អ្នកបាញ់សត្វធ្វើម្ហូប ស្ត្រី យុវជន ជនចំណូលថ្មីដែលគ្មានដី សហគមន៍តំបន់ការពារធម្មជាតិ អាជ្ញាធរមូលដ្ឋាន ប៉ូលីស ទាហាន |

